# ព្រះរាជក្រម

នស.រកម.១២៩៦-៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

*********

លេខ...៧៣...
ថ្ងៃទី...០១...ម៉ោង១១:៣០
បញ្ជូនទៅ...

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង ទេសរដ្ឋមន្ត្រី ទទួលបន្ទុកស្តារនីតិសម្បទា និងអភិវឌ្ឍន៍ និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ធ្នូ ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ
## ស្តីពីចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ១៩៩៧ ឱ្យប្រមូលចូលថវិកាទូទៅរបស់រដ្ឋនូវ ពន្ធដារ វិភាគទាន អាករ ផលទុននិងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវអំណោយ មូលនិធិឧបត្ថម្ភ និង ធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន..........................................................១.៤៩៦.៥០០ លានរៀល

និងត្រូវបែងចែកដូចតទៅ :

-ចំណូលជាប្រចាំ..........................................៨៨៥.០០០ លានរៀល

-ចំណូលជាមូលធន.......................................៦១១.៥០០ លានរៀល

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សម្រាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ត្រូវបានកំណត់ស្មើនឹង..............................១.៤៩៦.៥០០ លានរៀល

ដែលត្រូវបែងចែកដូចតទៅ :

-ចំណាយជាប្រចាំ........................................៨៧០.០០០ លានរៀល

-ចំណាយជាមូលធន......................................៦២៦.៥០០ លានរៀល

**មាត្រា ៣.-**

**ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សម្រាប់ចំណាយជាប្រចាំរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ត្រូវបានកំណត់ស្មើនឹង..............................៨៧០.០០០ លានរៀល**

**ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទនៃថវិកាដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។**

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧-១៩៩៩ ត្រូវបានកំណត់ស្មើនឹង...................................................៣.៨៨០.៨១០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមកម្មវិធី ឬតាមគំរោង និង តាមឆ្នាំ ដូចមានចែងក្នុងតារាង "គ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់ សម្រាប់ចំណាយជាមូលធននៃថវិការដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ត្រូវបានកំណត់ដូចតទៅ :

ក-វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស

-ឥណទានភ្ជាប់សន្យា..................................៧៣៣.០០០ លានរៀល

-ឥណទានទូទាត់.......................................៤៨៨.០០០ លានរៀល

ខ-វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស

-ឥណទានភ្ជាប់សន្យា..................................១២២.៨០០ លានរៀល

-ឥណទានទូទាត់.......................................១២២.៨០០ លានរៀល

គ-ការរំលស់បំណុលសាធារណៈ

-ឥណទានភ្ជាប់សន្យា..................................១៥.៧០០ លានរៀល

-ឥណទានទូទាត់.......................................១៥.៧០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងស្ថាប័នប្រហាក់ប្រហែលនីមួយៗនិងតាមជំពូកថវិកា ដូចមានចែកក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

ដើម្បីធានាការការទប់ទល់នឹងការបាត់តុល្យភាពថវិកា ដែលបណ្តាលមកពីចំណូលមិនគ្រប់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមទៅតាមមាត្រា ៤៥ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១.នស.៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ មានសិទ្ធិចាត់វិធានការរាំងខ្ទប់ ឥណទានលើចំណាយមិនចាំបាច់ នៅពេលណាដែលការប្រមូលពន្ធដារ ពន្ធនិងអាករលើពាណិជ្ជកម្មក្រៅប្រទេស ឬផលព្រៃឈើមិនគ្រប់តាមគម្រោងថវិកា ដែលរដ្ឋសភាបានអនុម័ត ហើយចំណូលមិនគ្រប់នេះ នេះតែបន្តរហូតដល់រយៈពេល ៣ខែ ។ នៅក្នុងលក្ខខណ្ឌនេះ ឥណទានរាំងខ្ទប់មិនមែនជាឥណទានទំនេរសម្រាប់រដ្ឋមន្ត្រីជាអាណាប័កដើមនិងអភិបាលខេត្ត ក្រុង ជាអាណាប័កផ្ទេរសិទ្ធិទៀតទេ ។

គ្រប់កិច្ចសន្យាចំណាយលើឥណទានដែលបានរាំងខ្ទប់ ត្រូវទុកជាមោឃៈនិងមិនមានអានុភាពអ្វីចំពោះរតនាគារទេ ។

## ជំពូកទី ២
## បទប្បញ្ញត្តិ
## ស្តីពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

**មាត្រា ៧.-**

ហាមឃាត់ដាច់ខាតមិនឱ្យប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែ ព្រមទាំងអាណាប័កផ្ទេរសិទ្ធិ ចាត់វិធានការទាំងឡាយណា ដែលនាំឱ្យកើនចំណាយលើឥណទានថវិកាទូទៅរបស់រដ្ឋ ដែលពុំមានចែងក្នុងច្បាប់ហិរញ្ញវត្ថុឬច្បាប់ អនុក្រឹត្យនិងបទបញ្ជាដែលមានពីមុនកិច្ចសន្យាចំណាយ ។

**មាត្រា ៨.-**

ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១.នស.៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានចាត់ទុកជាកំហុសនៃការគ្រប់គ្រង ដែលបានប្រព្រឹត្តចំពោះរដ្ឋដូចជា :

-រាល់អំពើដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិ ដូចមានចែងក្នុងជំពូកទី៣ ខាងក្រោមនេះ ។

-រាល់អំពើដែលបានចុះកិច្ចសន្យាចំណាយលើសឥណទានថវិកា ដែលបានអនុម័តដោយរដ្ឋសភាលើកលែងតែឥណទានដែលបានគ្រោងទុក សម្រាប់បើកប្រៀវត្សនិងប្រាក់វិភាជន៍សង្គម សេវាបំណុលនិងសងប្រាក់ខ្ចីដែលបានយល់ព្រមដោយរដ្ឋសភា ព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរជាតិ ។

-រាល់អំពើដែលជាកម្មវត្ថុ សម្រាប់បង្កើនទឹកប្រាក់ឥណទានថវិកា ដែលបានទទួលការអនុញ្ញាតពីរដ្ឋសភា ដោយពុំបានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ជាជាធរមាន និងដោយអនុសញ្ញាអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តយល់ព្រម

-រាល់កំហុសធ្ងន់ធ្ងរដែលនាំឱ្យមានការខាតបង់ប្រាក់កាសដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។

-រាល់សកម្មភាពគ្រប់គ្រងដែលប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យនិងបទបញ្ជាដែលអនុវត្តចំពោះចំណូលនិងចំណាយរបស់រដ្ឋ ។

**មាត្រា ៩.-**

ប្រធានស្ថាប័នរដ្ឋបាល អាណាប័កដើមខ្សែនិងអាណាប័កផ្ទេរសិទ្ធិ ព្រមទាំងមន្ត្រីរាជការនិងភ្នាក់ងាររដ្ឋត្រូវទទួលខុសត្រូវដោយផ្ទាល់លើការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ។

## ជំពូកទី ៣

## បទប្បញ្ញត្តិ

## ស្តីពីការខ្ចីនិងការធានារបស់រដ្ឋ

**មាត្រា ១០.-**

ចំនួនទឹកប្រាក់ជាអតិបរមា ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យខ្ចីមានកំរិតរហូតដល់ ១៦០.០០០.០០០S.D.R (មួយរយហុកសិបលាន អេសដេអែ) សម្រាប់ឆ្នាំ១៩៩៧។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រទានសិទ្ធិជាលាយល័ក្ខណ៍អក្សររបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរនៃរាជរដ្ឋាភិបាល ក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋឬលើការធានារបស់រដ្ឋ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទាន ដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ • ដោយមានការទាក់ទងជាមួយធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឱ្យលក់ប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ចំនួន ២៥.០០០ លានរៀល ដើម្បីបំបាត់នូវឱនភាពថវិកា ឬសម្រាប់ដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ ល័ក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់។ រាល់ការខ្ចីនិងការធានារបស់រដ្ឋក្រោមល័ក្ខខ័ណ្ឌពាណិជ្ជកម្ម សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៧ ត្រូវហាមឃាត់ ។

**មាត្រា ១១.-**

មិនអនុញ្ញាតឱ្យក្រសួងឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលប័ត្ររយៈពេលវែង មធ្យម- ខ្លី- ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

មាត្រា ១២.-

លំអិតទាំងឡាយនៃកិច្ចប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យ យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ជូនរដ្ឋសភារៀងរាល់ ៦ខែម្តង ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ១៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍
និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់